# បុព្វកថា

គោរព "ព្រះយេស៊ូលីឈើឆ្កាង" ជាពិធីមួយសម្រាប់ដាស់តឿនគ្រីស្តបរិស័ទ ឲ្យនឹកសញ្ជឹងនូវទុក្ខលំបាករបស់ព្រះយេស៊ូ ដែលបានបូជាព្រះជន្ម ក្នុងនាមមនុស្សទាំងអស់ថ្វាយព្រះបិតាដោយព្រះហឫទ័យស្រឡាញ់ជាទីបំផុត។

ម្យ៉ាងទៀត គ្រីស្តបរិស័ទត្រូវនឹកថា សព្វថ្ងៃនេះ នៅពេលមនុស្សណាម្នាក់ត្រូវគេមើលងាយ ទាត់ធាក់ ទះកំផ្លៀង វាយដំ កាត់ក្តីដាក់ទោស ធ្វើបាបសម្លាប់ចោល ពេលនោះព្រះគ្រីស្តក៏រងទុក្ខលំបាករួមជាមួយគេដែរ។ រឿងដែលកើតមានឡើងដល់ព្រះយេស៊ូកាលពីមុន ក៏ជារឿងរបស់មនុស្សយើងសព្វថ្ងៃនេះដែរ។

គ្រីស្តបរិស័ទអាចចាត់ចែងពិធីនេះតាមរបៀបផ្សេងៗគឺ៖

*១-អានអត្ថបទគម្ពីរដំណឹងល្អដែលរៀបរាប់អំពីព្រះយេស៊ូរងទុក្ខលំបាក (មថ* ***២៦****, ២០-****២៧****,៦០ ឬ មក* ***១៤****,១៧-****១៥****,៤៧ ឬ លក* ***២២****,១៤-****២៣****,៥៦ ឬ យហ* ***១៨-១៩****) ដោយនៅស្ងៀម ឬ ច្រៀងបទផ្សេងៗ ឬ អធិដ្ឋាន។*

*២-គ្រីស្តបរិស័ទដើររួមគ្នា ឬ ម្នាក់ឯងក្នុងព្រះវិហារ តាមព្រះយេស៊ូលីឈើឆ្កាង ហើយឈប់ជាដំណាក់ៗ (១៤ដំណាក់ តាមប្រពៃណីព្រះសហគមន៍) ទាំងអានអត្ថបទគម្ពីរ នឹកសញ្ជឹងដល់ទុក្ខលំបាករបស់ព្រះយេស៊ូ អធិដ្ឋាន និងច្រៀងផង។*

*៣-យើងអាចជ្រើសរើសតែ ៥ ឬ ៦ ដំណាក់ក៏បាន មិនចាំបាច់ធ្វើទាំងអស់ទេ។*

*ពេលចាប់ផ្តើមដំណាក់នីមួយៗ គ្រីស្តបរិស័ទក្រាបថ្វាយបង្គំ ហើយសូត្រថា៖*

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*

*ទាំងអស់គ្នា៖ ព្រះអង្គបានបូជាព្រះជន្ម ដើម្បីសង្គ្រោះយើងខ្ញុំ។*

# ពិធីគោរពព្រះយេស៊ូលីឈើឆ្កាង

## ពិធីប្រារព្ធ ៖

*-អ្នកណែនាំ ៖*

បពិត្រព្រះបិតាជាព្រះជាម្ចាស់!

យើងខ្ញុំសូមជ្រកកោនក្រោមម្លប់ព្រះបារមីព្រះអង្គ។ សូមទ្រង់ព្រះមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំ ឲ្យនឹកសញ្ជឹងអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ដែលទ្រង់បានចាត់ព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ ឲ្យយាងមកសង្គ្រោះមនុស្សលោក។

បពិត្រព្រះយេស៊ូគ្រីស្តជាអម្ចាស់!

យើងខ្ញុំបានធ្វើឲ្យព្រះអង្គរងទុក្ខលំបាកយ៉ាងសែនវេទនា។ យើងខ្ញុំសូមអង្វរព្រះអង្គសូមទ្រង់ព្រះមេត្តាប្រោសដល់អស់អ្នកដែលកំពុងរងទុក្ខលំបាកយ៉ាងធ្ងន់ធ្ងរ ដោយសារជំងឺរ៉ាំរ៉ៃរង់ចាំថ្ងៃស្លាប់ អស់អ្នកដែលត្រូវគេបោះបង់ចោល និងអស់អ្នកដែលធ្វើការយ៉ាងលំបាកហត់នឿយផង។

សូមព្រះអង្គប្រទានសេចក្តីសង្ឃឹម និងជីវិតដល់មនុស្សទាំងឡាយផង។



គេកាត់ទោសប្រហារជីវិតព្រះយេស៊ូ

# ដំណាក់ទី១
# គេកាត់ទោសប្រហារជីវិតព្រះយេស៊ូ

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រិស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*លោកពីឡាតមានប្រសាសន៍ទៅកាន់ជនជាតិយូដាថា៖ "មើលមនុស្សហ្នឹងហើយ!"។ កាលពួកនាយកបូជាចារ្យ និងកងរក្សាព្រះវិហារឃើញព្រះអង្គ គេនាំគ្នាស្រែកឡើងថា៖ "ឆ្កាងទៅ! ឆ្កាងទៅ!"។ ពេលលោកពីឡាតឮដូច្នេះ លោករឹតតែភ័យខ្លាចថែមទៀត។ ពួកនាយកបូជាចារ្យឆ្លើយថា៖ "ក្រៅពីព្រះចៅអធិរាជ យើងខ្ញុំគ្មានស្ដេចឯណាទៀតឡើយ!"។ ពេលនោះ លោកពីឡាតប្រគល់ព្រះយេស៊ូទៅឲ្យគេឆ្កាង។* (យហ ១៩,៤-១៦)

**អធិដ្ឋាន៖**

បពិត្រព្រះយេស៊ូជាអម្ចាស់!

លោកពីឡាតបានកាត់ទោសព្រះអង្គ ដ្បិតលោកមានចិត្តភ័យខ្លាច។ តែព្រះអង្គមានព្រះហឫទ័យសន្ដោសប្រណីជានិច្ច ដល់អស់អ្នកដែលគេបដិសេធព្រះអង្គ ដល់អស់អ្នកដែលកាត់សេចក្ដីមិនត្រឹមត្រូវតាមយុត្តិធម៌ ដ្បិតមានគេបញ្ជាពីលើ ឬ ដ្បិតគេភ័យខ្លាចបាត់បង់តំណែងក្នុងសង្គម។

**ច្រៀង៖**

*បន្ទរ៖ សូមព្រះជាម្ចាស់ទ្រង់ព្រះមេត្តា អាសូរករុណា និងប្រោសប្រណី*
*សូមទ្រង់ប្រទានព្រះពរជោគជ័យ ដោយព្រះហឫទ័យដ៏សប្បុរស។*

មនុស្សក្នុងពិភពលោកសាកល មុខជានឹងស្គាល់នូវការសង្គ្រោះ
ព្រមទាំងបានយល់នូវក្ដីសន្ដោស ជាបំណងខ្ពស់របស់ព្រះអង្គ។



ព្រះយេស៊ូលីឈើឆ្កាងឆ្ពោះទៅភ្នំលលាដ៍ក្បាល

# ដំណាក់ទី២
# ព្រះយេស៊ូលីឈើឆ្កាងឆ្ពោះទៅភ្នំលលាដ៍ក្បាល

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*លោកពីឡាតចង់បំពេញចិត្តបណ្ដាជន ក៏ដោះលែងបារ៉ាបាស។ បន្ទាប់ពីលោកបញ្ជាឲ្យគេវាយព្រះយេស៊ូនឹងរំពាត់រួចហើយ លោកក៏ប្រគល់ព្រះអង្គទៅឲ្យគេឆ្កាង។ ពួកទាហានបណ្ដើរព្រះយេស៊ូទៅក្នុងទីធ្លាបន្ទាយ។ គេយកអាវពណ៌ក្រហមទុំមកពាក់ថ្វាយព្រះអង្គ និងបំពាក់មកុដបន្លាលើព្រះសិរសាដែរ។ បន្ទាប់មកគេសំពះគោរពព្រះអង្គទាំងពោលចំអកថា៖ "សូមគោរពថ្វាយបង្គំស្ដេចយូដា"។ គេវាយព្រះសិរសាព្រះអង្គនឹងដំបង គេស្ដោះទឹកមាត់ដាក់ព្រះអង្គ ទាំងលុតជង្គង់ថ្វាយបង្គំព្រះអង្គថែមទៀតផង"។ (មក ១៥,១៥-២០)*

**អធិដ្ឋាន៖**

- ព្រះយេស៊ូ បានរងទុក្ខវេទនាព្រោះតែយើង

*បន្ទរ៖ សូមអាណិតអាសូរយើងខ្ញុំ។*

- ព្រះយេស៊ូ ទទួលយកការឈឺចាប់របស់យើង មកដាក់លើព្រះកាយព្រះអង្គ

*បន្ទរ៖ សូមអាណិតអាសូរយើងខ្ញុំ។*

- ព្រះយេស៊ូ ត្រូវគេចាក់ទម្លុះ ព្រោះតែការបះបោររបស់យើង

*បន្ទរ៖ សូមអាណិតអាសូរយើងខ្ញុំ។*

- ព្រះយេស៊ូ ត្រូវគេជាន់ឈ្លី ព្រោះតែអំពើទុច្ចរិតរបស់យើង

*បន្ទរ៖ សូមអាណិតអាសូរយើងខ្ញុំ។*

- ព្រះយេស៊ូ បានរងទារុណកម្ម ដើម្បីឲ្យយើងទទួលសេចក្ដីសុខសាន្ត ដោយសារស្នាមរបួសរបស់ព្រះអង្គ យើងក៏បានជាសះស្បើយ

*បន្ទរ៖ សូមអាណិតអាសូរយើងខ្ញុំ។*

(តាម អស ៥៣, ៣-៥)



ព្រះយេស៊ូដួលតាមផ្លូវ

# ដំណាក់ទី៣
# ព្រះយេស៊ូដួលតាមផ្លូវ

*អ្នកណែនាំ៖* ***យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត***
*ឆ្លើយ៖* ***ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។***

*ព្រះយេស៊ូមានព្រះបន្ទូលទៅបណ្ដាជនថា៖ "អ្នកណាចង់តាមខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួនរៀងរាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ"។ (លក ៩,២៣)*

*ព្រះយេស៊ូនាំលោកសិលា លោកយ៉ាកុប និងលោកយ៉ូហានទៅជាមួយ។ ពេលនោះ ព្រះអង្គចាប់ផ្ដើមស្លុតរន្ធត់ ព្រមទាំងចុកចាប់អន្ទះសាពន់ប្រមាណ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា៖ "ខ្ញុំព្រួយក្នុងចិត្តស្ទើរតែស្លាប់ អ្នករាល់គ្នានៅទីនេះសិនហើយ ចូរប្រុងស្មារតី"។ (មក ១៤,៣៣-៣៤)*

**អធិដ្ឋាន៖**

បពិត្រព្រះយេស៊ូជាអម្ចាស់! យើងខ្ញុំដឹងថា ព្រះអង្គគង់នៅក្បែរយើងខ្ញុំ សូមព្រះអង្គជួយណែនាំដំណើរជីវិតរបស់យើងខ្ញុំផង ពេលយើងខ្ញុំជួបឧបសគ្គដែលរារាំងមិនឲ្យយើងខ្ញុំដើរទៅមុខបាន។ សូមឲ្យយើងខ្ញុំចេះប្រុងស្មារតីគ្រប់ពេលវេលា ដ្បិតយើងខ្ញុំជាមនុស្សទន់ខ្សោយ។

បពិត្រព្រះយេស៊ូជាអម្ចាស់ សូមអាណិតអាសូរយើងខ្ញុំ។

**ច្រៀង៖** (បទពាក្យ៧)

- ខ្ញុំធ្លាក់ខ្លួនស្គមស្គាំងរីងរៃ ទុក្ខព្រួយរាល់ថ្ងៃទ្រូងឆាបឆួល
  ឈឺចាប់ជានិច្ចឥតប្រែប្រួល ខ្លួនខ្ញុំចង់ដួលកាយទោរទន់ ។
- ឱព្រះម្ចាស់អើយកុំបង់បោះ ចោលខ្ញុំឲ្យរស់ទាំងត្រដរ
  មេត្តាខ្ញុំផងសូមអង្វរ កុំយាងចេញចរខ្ញុំខ្លោចផ្សា ។
- ឱព្រះអម្ចាស់ព្រះសង្គ្រោះ សូមជួយឲ្យរស់ផុតមរណា
  យាងមកឆាប់ៗស្រង់សង្ខារ នោះទើបជីវាផុតក្សិណក្ស័យ ។

(ទន ៣៨)



ព្រះយេស៊ូជួបព្រះមាតារបស់ព្រះអង្គ

# ដំណាក់ទី៤
# ព្រះយេស៊ូជួបព្រះមាតារបស់ព្រះអង្គ

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*កាលព្រះយេស៊ូនៅកុមារ នាងម៉ារីសួរព្រះអង្គថា៖ "កូនអើយ! ហេតុអ្វីបានជាកូនធ្វើដូច្នេះ? ឪពុក និងម្ដាយព្រួយណាស់ខំដើររកកូន"។ ព្រះកុមារមានព្រះបន្ទូលតបថា៖ "ហេតុអ្វីបានជាលោកឪពុកអ្នកម្ដាយរកកូនយ៉ាងហ្នឹង? តើលោកឪពុកអ្នកម្ដាយមិនជ្រាបថា កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូនទេឬ?" (លក ២,៤៨-៤៩)*

## អធិដ្ឋាន៖

បពិត្រព្រះយេស៊ូជាអម្ចាស់! ក្មេងៗ និងយុវជនដែលត្រូវគេបោះបង់ចោល គេមិនរាប់រកនៅលើលោកនេះ តែងចោទសំណួរអំពីខ្លួនគេថា៖ "តើជីវិតខ្ញុំមានន័យដែរឬទេ?"។ ព្រះអង្គតែងអះអាងចំពោះយើងខ្ញុំថា៖ "គ្រប់ពេលដែលអ្នកសម្រាលទុក្ខលំបាករបស់អ្នកតូចតាចណាម្នាក់ នោះគឺអ្នកបានធ្វើចំពោះខ្ញុំហើយ"។ សូមព្រះគ្រីស្តជាអម្ចាស់ ជួយយើងខ្ញុំឲ្យមានចិត្តរឹងប៉ឹង ដើម្បីទៅរកអស់បងប្អូនដែលយើងខ្ញុំមិនចង់ជួប មិនចង់ឃើញនោះផង។

## ច្រៀង៖

*បន្ទរ៖ គ្រប់ពេលដែលអ្នករាល់គ្នា បានប្រព្រឹត្តអំពើអ្វី*
*ចំពោះអ្នកតូចតាចនោះ គឺអ្នករាល់គ្នាបានប្រព្រឹត្តចំពោះខ្ញុំដែរ។*

ប. នៅពេលខ្ញុំមានជំងឺ អ្នករាល់គ្នាសួរសុខទុក្ខខ្ញុំ
ហើយកាលខ្ញុំជាប់ឃុំឃាំង អ្នកក៏បានមកសួរខ្ញុំដែរ។
ស. បពិត្រព្រះអម្ចាស់តើ យើងខ្ញុំបានឃើញព្រះអង្គមានជំងឺ
ប. ឃើញជាប់ឃុំឃាំង
រួម. ហើយបានខិតខំមកសួរ សុខទុក្ខព្រះអង្គកាលពីពេលណា?



លោកស៊ីម៉ូន ជាអ្នកស្រុកគីរ៉ែនលីឈើឆ្កាងជំនួសព្រះយេស៊ូ

# ដំណាក់ទី៥
# លោកស៊ីម៉ូន ជាអ្នកស្រុកគីរ៉ែនលីឈើឆ្កាងជំនួសព្រះយេស៊ូ

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*នៅពេលគេបណ្ដើរព្រះយេស៊ូទៅ គេជួបបុរសម្នាក់ឈ្មោះស៊ីម៉ូន ជាអ្នកស្រុកគីរ៉ែន ដែលត្រឡប់ពីចម្ការ។ គេចាប់បង្ខំគាត់ឲ្យលីឈើឆ្កាងដើរតាមក្រោយព្រះយេស៊ូ។ (លក ២៣, ២៦)*

*ឱ! ព្រះជាម្ចាស់អើយ! ខ្ញុំជិតស្លាប់ហើយ ឯជីវិតខ្ញុំក៏ជិតលាចាកពីលោកនេះដែរ។ ខ្ញុំស្រែកឲ្យគេជួយគ្រប់ច្រកល្ហក តែគ្មាននរណាម្នាក់ជួយខ្ញុំទេ។ ខ្ញុំសង្ឃឹមរកមើលមនុស្សជួយ តែគ្មានឃើញនរណាសោះឡើយ។ (បសរ ៥១, ៦-៧)*

**អធិដ្ឋាន៖**

បពិត្រព្រះយេស៊ូជាអម្ចាស់! សូមព្រះអង្គបង្ហាត់យើងខ្ញុំឲ្យចេះជួយរំលែកទុក្ខពីបងប្អូនរបស់យើងខ្ញុំ ឲ្យយើងខ្ញុំត្រៀមខ្លួនសង្គ្រោះគេជានិច្ច ដោយមិនចាំបាច់គេសូមឡើយ សូមជួយយើងខ្ញុំឲ្យយកចិត្តទុកដាក់ចំពោះបងប្អូនឯទៀតៗ និងនៅពេលណាឈើឆ្កាងរបស់យើងខ្ញុំធ្ងន់ពេក សូមព្រះអង្គចាត់នរណាម្នាក់មកជួយយើងខ្ញុំផង។

**ច្រៀង៖**

- សូមជួយយើងខ្ញុំឲ្យចេះគិតគូរ ខំតស៊ូដើរតាមព្រះអង្គ
  ទោះបីយ៉ាប់យ៉ឺនលំបាកប្រាណ លុះដល់ឈើឆ្កាងបានរុងរឿង។

*បន្ទរ៖ រួមជាមួយព្រះយេស៊ូ ជាគំរូឲ្យយើងដើរតាម*
*រួមថ្វាយទៅកាន់ព្រះបិតា សូមទ្រង់មេត្តា មេត្តាយើងខ្ញុំ។*

- ពេលថ្ងៃខ្ញុំធ្វើការហត់នឿយ យប់មកដល់ហើយចិត្តខ្ញុំប៉ង
  ចង់រួមជាមួយព្រះអង្គផង នេះជាបំណងដ៏ថ្លៃថ្លា។



នាងវេរ៉ូនីកា យកកន្សែងជូតព្រះភ័ក្ត្រព្រះយេស៊ូ

# ដំណាក់ទី៦
# នាងវេរ៉ូនីកា យកកន្សែងជូតព្រះភ័ក្ត្រព្រះយេស៊ូ

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*លោកអេសាយបានប្រកាសអំពីព្រះគ្រីស្តថា៖ "ពេលមហាជនឃើញលោក គេព្រឺខ្លាចយ៉ាងខ្លាំង ព្រោះលោកលែងមានទ្រង់ទ្រាយជាមនុស្សទៀតហើយ។ នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ អ្នកបម្រើប្រៀបបាននឹងពន្លកមួយដែលដុះចេញពីដីហួតហែង។ លោកគ្មានរូបសម្បត្តិ គ្មានកិត្តិយសថ្លៃថ្នូរគួរឲ្យចាប់អារម្មណ៍ឡើយ ហើយលោកក៏គ្មានរូបរាងអ្វីគួរឲ្យទាក់ទាញចិត្តយើងដែរ។ លោកជាមនុស្សដែលត្រូវគេមើលងាយ គ្មាននរណារាប់រក។ លោកស្គាល់តែការឈឺចាប់ និងរងទុក្ខវេទនា លោកជាមនុស្សដែលគេខ្ពើម មិនហ៊ានសម្លឹងមើលទេ។ យើងបានមើលងាយលោក ហើយមិនរាប់រកលោកឡើយ"។ (អស ៥២, ១៤-៥៣, ២-៣)*

**អធិដ្ឋាន៖**

- លោកគ្មានរូបសម្បត្តិ គ្មានកិត្តិយសថ្លៃថ្នូរគួរឲ្យចាប់អារម្មណ៍ឡើយ

*ឆ្លើយ៖* យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក។

- លោកក៏គ្មានរូបរាងអ្វីគួរឲ្យទាក់ទាញចិត្តយើងដែរ

*ឆ្លើយ៖* យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក។

- លោកជាមនុស្សដែលត្រូវគេមើលងាយ គ្មាននរណារាប់រក

*ឆ្លើយ៖* យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក។

- លោកជាមនុស្សស្គាល់តែការឈឺចាប់ និងរងទុក្ខវេទនា

*ឆ្លើយ៖* យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក។

**ច្រៀង៖**

*បន្ទរ៖ ឱ! ព្រះយេស៊ូសូមមេត្តា លើកលែងទោស ឲ្យយើងខ្ញុំទាំងឡាយ។ (២ដង)*



ព្រះយេស៊ូដួលជាលើកទី២

# ដំណាក់ទី៧
# ព្រះយេស៊ូដួលជាលើកទី២

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*ព្រះយេស៊ូយាងទៅមុខបន្តិចក្រាបចុះដល់ដី ទូលអង្វរសូមឲ្យទុក្ខលំបាកនេះចេញឆ្ងាយពីព្រះអង្គទៅ បើសិនជាអាចកន្លងផុតទៅបាន។ ព្រះអង្គទូលថា៖ "អ័ប្បា ឱព្រះបិតាអើយ! ព្រះអង្គបានសម្រេចគ្រប់កិច្ចការទាំងអស់បាន សូមដកយកពែងនៃទុក្ខលំបាកនេះចេញឲ្យឆ្ងាយពីទូលបង្គំទៅ។ ប៉ុន្តែ សូមកុំតាមបំណងចិត្តទូលបង្គំឡើយ គឺសូមឲ្យបានសម្រេចតាមព្រះហឫទ័យព្រះអង្គវិញ"។ (មក ១៤, ៣៥-៣៦)*

**អធិដ្ឋាន៖**

"ឱ! ព្រះបិតាយើងខ្ញុំ ដ៏ខ្ពង់ខ្ពស់បំផុតអើយ!

សូមព្រះអង្គសម្រេចតាមព្រះគម្រោងការដ៏សប្បុរសរបស់ព្រះអង្គនៅលើផែនដីដូចជានៅស្ថានបរមសុខដែរ។

ឱ! ព្រះបិតាអើយ សូមព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំ ឲ្យរួមជាមួយព្រះគ្រីស្តផង។

សូមព្រះអង្គប្រោសឲ្យយើងខ្ញុំចេះទទួលស្គាល់ភាពទន់ខ្សោយ និងអំពើបាបរបស់ខ្លួន ហើយប្រែចិត្តវិលទៅរកព្រះអង្គវិញផង។

**ច្រៀង៖**

សូមព្រះជាម្ចាស់ទ្រង់ព្រះមេត្តា អាសូរករុណា និងប្រោសប្រណី
សូមទ្រង់ប្រទានព្រះពរជោគជ័យ ដោយព្រះហឫទ័យដ៏សប្បុរស។
មនុស្សលោកក្នុងផែនពិភពសាកល មុខជានឹងស្គាល់នូវការសង្គ្រោះ
ព្រមទាំងបានយល់នូវក្តីសន្តោស ជាបំណងខ្ពស់របស់ព្រះអង្គ។



ព្រះយេស៊ូ និងស្ត្រីៗនៅក្រុងយេរូសាឡឹម

# ដំណាក់ទី៨
# ព្រះយេស៊ូ និងស្ត្រីៗនៅក្រុងយេរូសាឡឹម

*អ្នកដែលនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*នៅពេលគេបណ្ដើរព្រះយេស៊ូទៅឆ្កាង បណ្ដាជនជាច្រើនបានដើរតាមព្រះអង្គទៅ ព្រមទាំងមានស្ត្រីៗគក់ទ្រូងយំសោកអាណិតព្រះអង្គផង។ ព្រះយេស៊ូងាកមកមានព្រះបន្ទូលទៅស្ត្រីទាំងនោះថា៖ "ស្ត្រីក្រុងយេរូសាឡឹមអើយ! កុំយំសោកអាណិតខ្ញុំធ្វើអ្វី ចូរយំសោកអាណិតខ្លួននាង និងកូននាងវិញទៅ"។ (លក ២៣,២៨)*

**អធិដ្ឋាន៖**

បពិត្រព្រះយេស៊ូជាអម្ចាស់!

ព្រះអង្គបានរងទុក្ខលំបាកយ៉ាងខ្លាំងនៅលើព្រះឈើឆ្កាង។ សូមព្រះអង្គប្រទានសេចក្ដីក្លាហានដល់អស់បងប្អូនយើងខ្ញុំដែលកំពុងរងទុក្ខវេទនា ដែលកំពុងអស់សង្ឃឹមផង។ ខ្ញុំដឹងថា មានតែព្រះអង្គទេ ដែលបបោសអង្អែលបងប្អូនយើងខ្ញុំដោយព្រះហឫទ័យស្ម័គ្រស្មោះ។

**ច្រៀង៖** (បទកាកគតិ)

- ក្រែងមានអ្នកជួយ តែឥតមានមួយ ចិត្តខ្ញុំសោកសៅ ចាំមើលអ្នកមក
  ល្ងងលោមនិត្យនៅ ទាំងដង្ហើយហៅ តែឥតមានមក ។
- សូមព្រះអង្គកុំ បោះបង់ចោលខ្ញុំ ជាជនទន់ទាប ឲ្យឃ្លាតចេញឆ្ងាយ
  ដូចអ្នកមានបាប សូមរស់ដ៏រាប ក្បែរព្រះឧត្ដម ។
- ខ្ញុំទ្រាំឲ្យគេ ប្រមាថដៀលជេរ មើលងាយពេកក្រៃ ព្រោះតែព្រះអង្គ
  ខ្មាសគេស្ទើរក្ស័យ អប់ឱនសិរី ព្រោះតែព្រះអង្គ។

(ទន ៦៩, ២១-១៨-៨)



ព្រះយេស៊ូដួលតាមផ្លូវជាលើកទីបី

# ដំណាក់ទី៩
# ព្រះយេស៊ូដួលតាមផ្លូវជាលើកទីបី

*អ្នកណែនាំ ៖* ***យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត***

*ឆ្លើយ ៖* ***ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។***

*ព្រះយេស៊ូយាងទៅរកពួកសាវ័ក ឃើញគេកំពុងដេកលក់ ព្រះអង្គមានព្រះបន្ទូលទៅលោកសិលាថា៖ "ស៊ីម៉ូនអើយម្តេចក៏ដេកលក់ដូច្នេះ? អ្នកនៅស៊ូទ្រាំប្រុងស្មារតីសូម្បីតែមួយម៉ោងក៏មិនបានដែរឬ? ចូរប្រុងស្មារតី ហើយអធិដ្ឋានកុំឲ្យចាញ់ការល្បួងឡើយ ចិត្តគំនិតប្រុងប្រៀបមែន ប៉ុន្តែកម្លាំងកាយនៅខ្សោយទេ"។ (មក ១៤, ៣៧-៣៨)*

*ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា បើអ្នករាល់គ្នាមិនប្រែចិត្តគំនិតទេ អ្នករាល់គ្នានឹងត្រូវវិនាសដូចគេជាមិនខាន"។ (លក ១៣, ៣)*

**អធិដ្ឋាន៖**

បពិត្រព្រះយេស៊ូជាអម្ចាស់!

អំពើក្បត់របស់យើងខ្ញុំច្រើនឥតគណនា មិនអាចរាប់អស់បានឡើយ! តែយើងខ្ញុំដឹងច្បាស់ថា គ្រប់ពេលដែលយើងខ្ញុំជួបបរាជ័យ ឬ លះបង់ព្រះអង្គ ពេលនោះព្រះអង្គនៅតែមានព្រះបន្ទូលមកយើងខ្ញុំថា៖ "ចូរក្រោកឡើង ដើរទៅមុខទៀត ចូរជឿទុកចិត្តលើខ្ញុំចុះ មិនត្រូវភ័យខ្លាចឡើយ!"។

**ច្រៀង៖**

កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច ព្រោះយើងមានព្រះម្ចាស់គង់នៅជាមួយយើង
កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច មានព្រះម្ចាស់បានហើយ។
កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច ព្រោះយើងមានព្រះម្ចាស់គង់នៅជាមួយយើង
កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច មានព្រះម្ចាស់បានហើយ។



ព្រះយេស៊ូត្រូវគេដោះសម្លៀកបំពាក់

# ដំណាក់ទី១០
# ព្រះយេស៊ូត្រូវគេដោះសម្លៀកបំពាក់

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*ក្រោយពីឆ្កាងព្រះយេស៊ូរួចហើយ ពួកទាហានយកសម្លៀកបំពាក់របស់ព្រះអង្គមកធ្វើជាបួនចំណែក ចែកគ្នាម្នាក់មួយចំណែកៗ។ រីឯអាវវែងព្រះអង្គវិញ ជាអាវធ្វើពីក្រណាត់តែមួយផ្ទាំង គ្មានថ្នេរសោះតាំងពីលើដល់ក្រោម។ ដូច្នេះ គេនិយាយគ្នាថា៖ "កុំហែកអាវនេះធ្វើអ្វី យើងចាប់ឆ្នោតវិញ ដើម្បីឲ្យដឹងថា អាវនេះនឹងបានទៅលើអ្នកណា"។ ពួកទាហានធ្វើដូច្នេះ ស្របតាមសេចក្តីដែលមានចែងទុកក្នុងគម្ពីរមកថា៖ "គេបានយកសម្លៀកបំពាក់របស់ទូលបង្គំចែកគ្នា ហើយចាប់ឆ្នោតយកអាវរបស់ទូលបង្គំ"។ (យហ ១៩,២៣-២៤)*

**អធិដ្ឋាន៖**

ឱ! ព្រះយេស៊ូជាអម្ចាស់អើយ! ព្រះអង្គស្ថិតនៅចំពោះភ្នែកបណ្តាជនទាំងរាងកាយអាក្រាត។ ទណ្ឌកម្មគ្រប់យ៉ាងដែលព្រះអង្គទទួល គឺជាមេរៀនជួយយើងខ្ញុំឲ្យចេះបន្ទាបខ្លួន លះបង់កិលេសតណ្ហាដែលរារាំងដំណើរជីវិតរបស់យើងខ្ញុំ។

ឱ! ព្រះយេស៊ូជាអម្ចាស់អើយ! សូមបំភ្លឺដួងចិត្តយើងខ្ញុំឲ្យចេះស្រឡាញ់ខ្មាំងសត្រូវ ដូចព្រះអង្គស្រឡាញ់យើងខ្ញុំផង។

**ច្រៀង៖**

*បន្ទរ៖ ឱ! ព្រះយេស៊ូសូមមេត្តា លើកលែងទោស ឲ្យយើងខ្ញុំទាំងឡាយ។*

ឱ! ជនកម្សត់ ម្តេចក៏ប្រាសព្រាត់ពីព្រះយេស៊ូ ចូរមកយ៉ាងឆាប់
មកយ៉ាងប្រញាប់ សូមទ្រង់លើកលែងទោស។




ទាហានឆ្កាងព្រះយេស៊ូ

# ដំណាក់ទី១១
# ទាហានឆ្កាងព្រះយេស៊ូ

*អ្នកណែនាំ៖* *យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*

*ឆ្លើយ៖* *ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*លុះដល់កន្លែងមួយដែលគេហៅថា៖ "ភ្នំលលាដ៍ក្បាល" គេឆ្កាងព្រះយេស៊ូនៅទីនោះ ហើយគេក៏ឆ្កាងអ្នកទោសទាំងពីរនាក់នៅទីនោះដែរ ម្នាក់នៅខាងស្តាំព្រះអង្គ ម្នាក់ទៀតនៅខាងឆ្វេងព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ឱ! ព្រះបិតាអើយ! សូមព្រះអង្គអត់ទោសឲ្យអ្នកទាំងនេះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ"។* *(លូកា ២៣,៣៣-៣៤)*

**អធិដ្ឋាន៖**

ឱ! ព្រះយេស៊ូជាអម្ចាស់អើយ!

យើងខ្ញុំសូមអង្វរព្រះអង្គសម្រាប់អស់អ្នកដែលទទួលរងគ្រោះដូចព្រះអង្គ គឺអស់អ្នកដែលត្រូវគេជិះជាន់សង្កត់សង្កិន ត្រូវគេធ្វើឃាត ត្រូវគេចាប់ជំរិត ត្រូវគេប្រមាថមើលងាយដូចសត្វធាតុ និងសម្រាប់អស់កុមារ ដែលខ្វះការស្រឡាញ់ថ្នាក់ថ្នមពីឪពុកម្តាយ។

**ច្រៀង៖**

- នេះជាឈើ ដែលគេឆ្កាងព្រះយេស៊ូគ្រីស្ត
  គេបានធ្វើគុតព្រះសង្គ្រោះមនុស្សលោក នៅលើឈើនេះ!
- យើងខ្ញុំសូមក្រាបបង្គំព្រះឈើឆ្កាង។ (២ដង)




ព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង

# ដំណាក់ទី១២
# ព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំស្រេកទឹក" ដើម្បីឲ្យស្របតាមសេចក្តីគ្រប់ប្រការដែលមានចែងទុកក្នុងគម្ពីរ។ នៅទីនោះ មានក្រឡមួយមានទឹកខ្មេះពេញ។ ពួកទាហានយកសារាយស្ងួតជ្រលក់ទឹកខ្មេះដោក រួចរំនឹងចុងត្រែងមួយដើម រុញទៅដល់ព្រះឱស្ឋរបស់ព្រះអង្គ។ កាលព្រះយេស៊ូបានសោយទឹកខ្មេះហើយ ព្រះអង្គមានព្រះបន្ទូលថា៖ "ខ្ញុំបានសម្រេចសព្វគ្រប់អស់ហើយ" ព្រះអង្គក៏ឱនព្រះសិរសាចុះ ហើយប្រគល់ព្រះវិញ្ញាណទៅ។ (យហ ១៩,២៨-៣០)*

**អធិដ្ឋាន៖**

- ព្រះជាម្ចាស់ស្រឡាញ់យើងហួសពីការស្មាន៖ មិនមែនយើងទេ ដែលបានស្រឡាញ់ព្រះអង្គ គឺព្រះអង្គទេតើដែលបានស្រឡាញ់យើងជាមុន

*ទាំងអស់គ្នា៖ ព្រះអង្គទេតើដែលបានស្រឡាញ់យើងជាមុន។*

- ព្រះបិតាបានចាត់ព្រះបុត្រាឲ្យយាងមកបូជាព្រះជន្មលោះយើងឲ្យរួចពីបាប

*ទាំងអស់គ្នា៖ ព្រះអង្គទេតើដែលបានស្រឡាញ់យើងជាមុន។*

- ព្រះជាម្ចាស់បានស្រឡាញ់យើងដល់កម្រិតនេះទៅហើយ ដូច្នេះយើងក៏ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដែរ

*ទាំងអស់គ្នា៖ ព្រះអង្គទេតើដែលបានស្រឡាញ់យើងជាមុន។*

- រីឯយើងវិញ យើងមានចិត្តស្រឡាញ់ព្រះអង្គដែលបានស្រឡាញ់យើងជាមុន

*ទាំងអស់គ្នា៖ ព្រះអង្គទេតើដែលបានស្រឡាញ់យើងជាមុន។*

(១យហ ៤,១០-១១.១៩)។

**ច្រៀង៖**

ទីណាមានមេត្តា និងចិត្តស្រឡាញ់! ទីណាមានមេត្តា ព្រះអម្ចាស់គង់ជាមួយ។



គេដាក់ព្រះសពព្រះយេស៊ូចុះពីឈើឆ្កាង

# ដំណាក់ទី១៣
# គេដាក់ព្រះសពព្រះយេស៊ូចុះពីឈើឆ្កាង

*អ្នកណែនាំ៖ **យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត***
*ឆ្លើយ៖ **ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។***

*នាងម៉ារីឈរនៅក្បែរឈើឆ្កាង។ ថ្ងៃនេះជាថ្ងៃរៀបចំបុណ្យចម្លង ជនជាតិយូដាមិនចង់ឲ្យមានសាកសពជាប់នឹងឈើឆ្កាងនៅថ្ងៃសប្ប័ទឡើយ ព្រោះជាថ្ងៃបុណ្យធំ។ ហេតុនេះហើយបានជាគេសុំលោកពីឡាត ចេញបញ្ជាទៅទាហានឲ្យបំបាក់ជើងអ្នកជាប់ឆ្កាង ហើយយកសាកសពចុះមក។ ពួកទាហានវាយបំបាក់ជើងអ្នកទោសទីមួយ និងអ្នកទោសទីពីរ។ លុះមកដល់ព្រះយេស៊ូ គេឃើញព្រះអង្គសោយទិវង្គតផុតទៅហើយ គេមិនបំបាក់ព្រះបាទាព្រះអង្គទេ ប៉ុន្តែទាហានម្នាក់យកលំពែងចាក់ត្រង់ចន្លោះឆ្អឹងជំនីរព្រះអង្គ ស្រាប់តែមានទឹក និងលោហិតហូរចេញមួយរំពេច។ សាវ័កម្នាក់ដែលបានឃើញ ធ្វើបន្ទាល់អំពីហេតុការណ៍នេះ ហើយសក្ខីភាពរបស់គាត់ពិតប្រាកដមែន ដើម្បីឲ្យអ្នករាល់គ្នាជឿដែរ។ ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែលមានចែងទុកក្នុងគម្ពីរថា៖ "គ្មានឆ្អឹងណាមួយរបស់លោក ត្រូវបែកបាក់ឡើយ"។ (យហ ១៩,៣១-៣៧)*

## អធិដ្ឋាន៖

បពិត្រព្រះនាងម៉ារី! សូមព្រះនាងជួយយើងខ្ញុំឲ្យចេះរង់ចាំព្រះគ្រីស្ត និងចេះទទួលអ្នកដទៃ ដូចទទួលបងប្អូនបង្កើត។ សូមជួយយើងខ្ញុំឲ្យទទួលស្គាល់អ្នកដទៃទុកជារូបតំណាងរបស់ព្រះយេស៊ូ ដែលប្រទានសេចក្តីសង្ឃឹមក្នុងជីវិតយើងខ្ញុំផង។

## ច្រៀង៖

មាតារបស់ព្រះអង្គ រងទុក្ខឈឺចាប់ខ្លោចផ្សា នៅក្បែរឈើឆ្កាង
ពេញទាំងឱរាមេត្តា អាណិតបុត្រថ្លៃ ដែលរងទណ្ឌកម្ម
ដោយមិនចេញស្តី ដើម្បីសង្គ្រោះ មនុស្សលោកីយ៍។



គេដាក់ព្រះសពព្រះយេស៊ូទៅក្នុងផ្នូរ

# ដំណាក់ទី១៤
# គេដាក់ព្រះសពព្រះយេស៊ូនៅក្នុងផ្នូរ

*អ្នកណែនាំ៖ យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះគ្រីស្ត*
*ឆ្លើយ៖ ព្រះអង្គបានបូជាព្រះជន្មដើម្បីសង្គ្រោះយើងខ្ញុំ។*

*លោកយ៉ូសែប ជាអ្នកស្រុកអារីម៉ាថេ បានទៅសុំច្បាប់ពីលោកពីឡាត យកព្រះសពព្រះយេស៊ូ។ លោកពីឡាតអនុញ្ញាតឲ្យ ហើយលោកយ៉ូសែបក៏មកដោះព្រះសពយកទៅ។ ឯលោកនីកូដេម ដែលមកគាល់ព្រះយេស៊ូទាំងយប់កាលពីមុន ក៏បានមកដែរ។ លោកយកជ័រល្វីងទេស លាយនឹងគ្រឿងក្រអូបប្រមាណជាកន្លះហាបមកផង។ លោកទាំងពីរយកព្រះសពព្រះយេស៊ូមករុំនឹងសំពត់ស្បៃ អប់គ្រឿងក្រអូបតាមទំនៀមទម្លាប់ពិធីបញ្ចុះសពរបស់ជនជាតិយូដា។*

*នៅកន្លែងគេឆ្កាងព្រះយេស៊ូ មានសួនឧទ្យានមួយ ក្នុងសួននោះ មានផ្នូរមួយថ្មី ពុំទាន់ដែលដាក់សពណានៅឡើយ។ គេដាក់ព្រះយេស៊ូនៅក្នុងផ្នូរនោះ ព្រោះនៅជិតស្រាប់។ (យហ ១៩,៣៨-៤២)*

*ពួកស្ត្រីដែលមកតាមព្រះអង្គតាំងពីស្រុកកាលីឡេ ក៏ទៅជាមួយលោកយ៉ូសែបដែរ។ នាងបានឃើញផ្នូរ ហើយឃើញរបៀបដែលគេដាក់ព្រះសពព្រះយេស៊ូផង។ (លក ២៣, ៥៥)*

**អធិដ្ឋាន៖**

- យើងទាំងអស់គ្នាដែលបានទទួលពិធីជ្រមុជទឹក យើងបានជ្រមុជរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត

*ទាំងអស់គ្នា៖ យើងបានជ្រមុជរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត។*

- ហេតុនេះ ដោយពិធីជ្រមុជទឹកដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ

*ទាំងអស់គ្នា៖  យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ។*

- ព្រះគ្រីស្តមានព្រះជន្មថ្មី ដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើងក៏ត្រូវរស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ

*ទាំងអស់គ្នា៖  យើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ។*

- ប្រសិនបើយើងបានរួមស្លាប់ជាមួយព្រះអង្គដែលសោយទិវង្គត យើងក៏នឹងបានរួមជាមួយព្រះអង្គដែលមានព្រះជន្មថ្មីដែរ

*ទាំងអស់គ្នា៖  យើងក៏នឹងបានរួមជាមួយព្រះអង្គដែលមានព្រះជន្មថ្មីដែរ។*

(រម ៦,៣-៥)

# គោរពព្រះគ្រីស្ទជាអម្ចាស់

*បន្ទរ៖ គោរពព្រះគ្រីស្ទជាអម្ចាស់ នាំគ្នាប្រកាសយ៉ាងគ្រឹកគ្រាំ*
*លើកតម្កើងសិរីយ៉ាងថ្កើងថ្កុំ បង្គំព្រះម្ចាស់ជាបិតា។*

១- ទោះបីជាព្រះគ្រីស្ទមានឋានៈ ស្មើព្រះជាម្ចាស់នោះយ៉ាងណា
ក៏ព្រះអង្គមិនយកព្រះចេស្ដា ប្រើជាប្រយោជន៍ព្រះអង្គឡើយ
គឺព្រះអង្គទ្រង់បានលះបង់ អំណាចព្រះអង្គពុំសោកស្ដាយ
ព្រះអង្គទ្រង់បានបន្ទាបកាយ ក្លាយជាខ្ញុំបម្រើព្រះជាម្ចាស់។

២- ព្រះគ្រីស្ទទ្រង់ដាក់អង្គជាសាមញ្ញ ឲ្យមនុស្សផងឃើញដោយភ្នែកច្បាស់
មកជាសភាពមនុស្សមិនប្ដូរផ្លាស់ បេះបិទទាំងសព្វគ្រប់ប្រការ
ព្រះគ្រីស្ទបានបន្ទាបអង្គទៀត ធ្វើតាមឱវាទដ៏បវរ
នៃព្រះជាម្ចាស់បានបញ្ជា រហូតផុតជន្មាលើឈើឆ្កាង។

៣- ដោយហេតុនេះហើយទើបព្រះជាម្ចាស់ តម្កើងព្រះគ្រីស្ទហួសប្រមាណ
ហើយប្រោសប្រទាននូវព្រះនាម ព្រះគ្រីស្ទថ្កើងថ្កានជាអម្ចាស់
ដើម្បីឲ្យសត្វលោកទាំងឡាយ មនុស្សរាល់រូបកាយគ្រប់ជាតិសាសន៍
ទាំងពួកទេវទូតស្ថានបរមសុខ ច្រៀងកោតសរសើរថ្វាយបង្គំ។

# ចម្រៀងផ្សេងៗ

*(២ ធីម៉ូថេ ២,៨.១១-១៣)* *បទពាក្យ ៧*

៨- ចូរនឹកដល់ព្រះយេស៊ូនោះ មានព្រះជន្មរស់ឡើងវិញផង
ព្រះអង្គជាប់ព្រះញាតិវង្ស នៃដាវីឌអង្គម្ចាស់ក្សត្រា ។
១១- ពាក្យនេះគួរឲ្យយើងជឿជាក់ ដោយឥតលៀមលាក់យ៉ាងច្បាស់ថា
ប្រសិនបើយើងគ្រប់កាយា ព្រមរួមវាសនានឹងព្រះអង្គ ។
បើយើងព្រមរួមរស់រួមស្លាប់ នោះពិតជាគាប់ពេកកន្លង

យើងនឹងបានរស់ជីវិតផង រួមនឹងព្រះអង្គគ្មានកែប្រែ ។

១២- បើយើងជាអ្នកចេះស៊ូទ្រាំ ទោះជាយូរឆ្នាំយូរថ្ងៃខែ
នោះព្រះជាម្ចាស់នឹងគង់ក្បែរ ឲ្យសោយរាជ្យដែរជាមួយទ្រង់។
តែបើយើងមិនព្រមទទួល មិនព្រមស្រុះស្រួលស្គាល់ព្រះអង្គ
ពេលនោះព្រះជាអម្ចាស់ទ្រង់ នឹងមិនស្គាល់យើងវិញម្តងដែរ។

១៣- ប្រសិនបើយើងមិនស្មោះត្រង់ នោះព្រះអង្គគង់មិនកែប្រែ
ស្មោះត្រង់ជានិច្ចក៏ព្រោះតែ ទ្រង់មិនងាកបែរនៅតែស្មោះ។

## កុំឲ្យរន្ធត់ចិត្ត

កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច ព្រោះមានព្រះម្ចាស់
គង់នៅជាមួយយើង កុំឲ្យរន្ធត់ចិត្ត កុំឲ្យយើងភ័យខ្លាច
មានព្រះអម្ចាស់បានហើយ។

## ព្រះយេស៊ូសូមកុំភ្លេចខ្ញុំ

ព្រះយេស៊ូ! សូមកុំភ្លេចខ្ញុំ! ពេលព្រះអង្គយាងមកគ្រងរាជ្យ (ពីរដង)។

## ពិធីគោរពព្រះយេស៊ូលីឈើឆ្កាង

ព្រះអម្ចាស់ខ្ញុំដឹងច្បាស់ហើយថា ព្រោះយើងខ្ញុំទើបព្រះអង្គក្ស័យ
ដោយរងទុក្ខលំបាកឥតចេញស្តី ខ្ញុំសូមទោសសូមទ្រង់មេត្តា។
អំពើអាក្រក់ខ្ញុំច្រើនឥតគណនា ធ្វើឲ្យព្រះម្ចាស់ព្រួយព្រះហឫទ័យ
ម្តេចឡើយក៏ខ្ញុំនៅរឹងទទឹង មិនចាប់ភ្លឹកលន់តួព្រះអង្គ ។

## ឱ! ជនកម្សត់

១- ឱ! ជនកម្សត់ ម្តេចក៏ប្រាសព្រាត់ ពីព្រះយេស៊ូ ចូរមកយ៉ាងឆាប់
មកយ៉ាងប្រញាប់ សូមទ្រង់លើកលែងទោស។

*បន្ទរ៖ ឱ! ព្រះយេស៊ូសូមមេត្តា លើកលែងទោស ឲ្យយើងខ្ញុំទាំងឡាយ។*

២-　ខ្ញុំបាត់ស្មារតី　បាត់ទាំងសិរី　ធ្លាក់ខ្លួនក្សិណក្ស័យ　ព្រោះតែបាបកម្ម
　　ខុសព្រះបណ្ដាំ　នៃព្រះអម្ចាស់។
៣-　រាល់ទិនទិវា　ខ្មាំងមកយាយី　គ្រប់ទាំងទិសទី　ពីទីជម្រៅ
　　យើងខ្ញុំស្រែកហៅ　សូមឲ្យព្រះអង្គជួយ។

## យើងខ្ញុំសូមក្រាបបង្គំ

*បន្ទរ៖　យើងខ្ញុំសូមក្រាបបង្គំ　　គោរពដល់ព្រះឧត្ដម*
*ដែលបានប្រោសលោះលោកា　　ដោយបានបូជាព្រះជន្ម។*

១-　គ្រាប់ស្រូវធ្លាក់នៅលើដី　　ឧបមេយ្យបើមិនងាប់ទៅ
　　គ្រាប់នៅតែមួយដដែល　　មិនអាចបង្កើតផលឡើយ។
២-　អ្នកណាស្រឡាញ់ជីវិត　　អ្នកនោះពិតជាបាត់វា
　　អ្នកដែលស្ម័គ្រចិត្តលះបង់　　នឹងរក្សាជីវិតគង់។
៣-　អ្នកណាចង់បម្រើខ្ញុំ　　អ្នកនោះនឹងខំមកតាម
　　រីអ្នកដែលបានបម្រើ　　ព្រះបិតាតម្កើងគេ។

## សូមមេត្តាប្រោសយើងខ្ញុំ

*បន្ទរ៖　សូមមេត្តាប្រោសយើងខ្ញុំ　　ឱ! ព្រះជាអម្ចាស់*
*ដែលបានរងទុក្ខ　　និងសង្គ្រោះលោកា*

១-　សូមប្រោសយើងខ្ញុំ　ឱ! ព្រះជាអម្ចាស់　ព្រោះយើងខ្ញុំបានធ្វើអាក្រក់។
២-　សូមប្រោសយើងខ្ញុំ ឱ! ព្រះជាអម្ចាស់ ដែលបានសន្ដោសប្រោសលោកា។
៣-　សូមប្រោសយើងខ្ញុំ ឱ! ព្រះជាអម្ចាស់ ដែលបានបូជាព្រះជន្មសម្រាប់លោកា។
៤-　សូមប្រោសយើងខ្ញុំ ឱ! ព្រះជាអម្ចាស់ ដែលបានប្រទានជីវិតឲ្យលោកាវិញ។